ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១១

លេខ:១៥៦ ក្រ.ក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម និងសេវាកម្មសៀវភៅ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

-បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១**: ប្រកាសនេះមានគោលបំណងគ្រប់គ្រងអាជីវកម្មនិងសេវាកម្មសៀវភៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សៀវភៅ សំដៅកម្រងក្រដាសដែលមានបោះពុម្ពអក្សរ ឬនិងរូបភាព មានទំហំនិងកម្រាស់តាមសាច់រឿងដែលសរសេររៀបរាប់នូវរឿងរ៉ាវផ្សេងៗ មានក្របខាងក្រៅ មានចំណងជើង និងមានអ្នកនិពន្ធជាម្ចាស់កម្មសិទ្ធ។

**ប្រការ២**: ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសិទ្ធិពិនិត្យលើខ្លឹមសារអត្ថបទអក្សរសាស្ត្រ អក្សរសិល្ប៍ និង រូបភាពគ្រប់បែបយ៉ាងដែលមានលើទំព័រសៀវភៅទាំងអស់ ក្នុងគោលបំណងដើម្បីថែរក្សា ការពារនិងលើកតម្កើងវប្បធម៌ជាតិ។

រាល់ខ្លឹមសារសៀវភៅដែលនិយាយមិនល្អ ប៉ះពាល់ដល់ព្រះកិត្តិនាមព្រះមហាក្សត្រ ជំនឿសាសនា វប្បធម៌វីរបុរសជាតិ ការរើសអើងជាតិសាសន៍ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណត្រូវហាមឃាត់។

**ប្រការ៣**: ខ្លឹមសារដែលមានចែងក្នុងប្រការ ២ មិនសំដៅដល់សៀវភៅគ្រប់ប្រភេទ ដែលបោះពុម្ពដោយស្ថាប័នជំនាញក្នុងទិសដៅអប់រំសិក្សា មិនធ្វើអាជីវកម្ម ហើយដែលជាសមត្ថកិច្ចរបស់ស្ថាប័ននោះជាអ្នកទទួលខុសត្រូវ។

**ប្រការ៤**: គ្រប់សៀវភៅទាំងអស់ដែលបោះពុម្ព ដាក់លក់តាមបណ្ណាគារ ឬតាមគ្រប់ទីតាំងអាជីវកម្មលក់សៀវភៅត្រូវមានបញ្ជាក់ឈ្មោះអ្នកនិពន្ធ ចំនួនបោះពុម្ព ឈ្មោះរោងពុម្ព និងចុះលេខសៀវភៅតាមខ្នាតអន្តរជាតិ( ISBN )។

**ប្រការ៥**: សៀវភៅគ្រប់ប្រភេទ ដែលជាស្នាដៃរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងបោះពុម្ពដើម្បី គោលដៅអាជីវកម្ម ទោះក្នុងបែបផែនអ្វីក៏ដោយត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ក្នុងករណីចាំបាច់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអាចស្នើសុំក្រសួងពាក់ព័ន្ធដើម្បីសហការ។

**ប្រការ៦**: ដើម្បីងាយស្រួលសម្គាល់ជាម្ចាស់កម្មសិទ្ធិ ម្ចាស់ស្នាដៃតែងនិពន្ធសៀវភៅគ្រប់ប្រភេទ ត្រូវសុំចុះបញ្ជីរក្សាសិទ្ធិស្របច្បាប់នៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**ប្រការ៧**: ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាម្ចាស់កម្មសិទ្ធិលើស្នាដៃតែងនិពន្ធសៀវភៅគ្រប់ប្រភេទដែលគ្មានមតិកស្មាសន៍ ។ រាល់ការយកស្នាដៃគ្មានមតិកសាសន៍ទៅបោះពុម្ព ផ្សព្វផ្សាយត្រូវសុំការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៨**: សៀវភៅគ្រប់ប្រភេទជាភាសាជាតិ និងភាសាបរទេស ដែលយកទៅធ្វើអាជីវកម្មតាមបណ្ណាគារ ទីតាំងអាជីវកម្មលក់សៀវភៅក្នុងទីផ្សារ ឬ តាមទីសាធារណៈ ត្រូវតែជាសៀវភៅដែលមានចុះបញ្ជីរក្សាសិទ្ធិអ្នកនិពន្ធត្រឹមត្រូវ។

**ប្រការ៩**: បណ្ណាគារ ទីតាំងអាជីវកម្មលក់សៀវភៅ ក្នុងទីផ្សារ ឬតាមទីសាធារណៈ មិនត្រូវបានអនុញ្ញាតឲ្យយកសៀវភៅថតចម្លងមកដាក់លក់ក្នុងកន្លែងធ្វើអាជីវកម្មរបស់ខ្លួន។

**ប្រការ១០**: ការបើកបណ្ណាគារ ឬ ទីតាំងអាជីវកម្ម លក់សៀវភៅគ្រប់ប្រភេទ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ឬតាមការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខណ្ឌ ស្រុកគោលដៅដែលបានទទួលប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការប្រកបអាជីវកម្ម នាំចេញ នាំចូល សៀវភៅគ្រប់ប្រភេទ ត្រូវមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ១១**: រាល់ការអនុញ្ញាតធ្វើអាជីវកម្ម និងសេវាកម្មសៀវភៅត្រូវមានកម្រៃសេវាកម្ម ដែលកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្មរបស់ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខណ្ឌ ស្រុកគោលដៅ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ១២**: នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសៀវភៅ និងការអាន ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ